# សំណួរ និងចម្លើយ

**សំណួរ ៖** តើហេតុអ្វីមានការវាយតម្លៃច្រើន?

**ចម្លើយ ៖** WAC 388-310-1450 ចែងថា ឪពុកម្ដាយក្នុងការមានផ្ទៃពោះដល់ផ្លូវការងារត្រូវតែចូលរួមក្នុងការវាយតម្លៃជាមួយអ្នកឯកទេសបុគ្គលិកសង្គមនៃក្រសួងសេវាកម្មសង្គម និងសុខាភិបាលដើម្បីកំណត់សកម្មភាពមួយណាដែលសាកសមបំផុតសម្រាប់តម្រូវការរបស់អ្នក ។ ការវាយតម្លៃទាំងនេះនឹងត្រូវធ្វើឡើងនៅចំណុចខុសៗគ្នាក្នុងពេលមានផ្ទៃពោះ (ពេលដែលក្រសួងដឹងថាអ្នកមានផ្ទៃពោះ ឬមានកូនអាយុក្រោមមួយឆ្នាំ និងក្រោយពីសម្រាល) ដើម្បីកំណត់ការផ្លាស់ប្ដូរនានាក្នុងស្ថានភាពគ្រួសារអ្នក និងដើម្បីប្រាកដថាសកម្មភាពដែលតម្រូវឲ្យធ្វើនៅតែសមរម្យ ។ ឧទាហរណ៍ តម្រូវការរបស់អ្នកក្នុងត្រីមាសទីបីអាចខុសគ្នាខ្លាំងពីតម្រូវការរបស់អ្នកក្រោយអ្នកសម្រាល ។ ពួកយើងចង់ធានាថាតម្រូវការ WorkFirst របស់អ្នកបន្តបំពេញតម្រូវការរបស់អ្នក ។

**សំណួរ ៖** តើមានអ្វីកើតឡើង បើខ្ញុំមិនបានចូលរួមការណាត់ជួបវាយតម្លៃ?

**ចម្លើយ ៖** បើអ្នកមិនបានចូលរួមក្នុងការវាយតម្លៃ ពួកយើងនឹងបន្តជាមួយដំណើរការត្រឹមត្រូវដើម្បីកំណត់ថាតើអ្នកមានមូលហេតុសមរម្យសម្រាប់ការមិនចូលរួម ឬអត់ ។ បើអ្នកមិនមានមូលហេតុត្រឹមត្រូវទេ អ្នកនឹងត្រូវដាក់ពិន័យ និងជំនួយសាច់ប្រាក់ WorkFirst របស់អ្នកនឹងត្រូវបានកាត់បន្ថយ ។

**សំណួរ ៖** តើមានតែខ្ញុំម្នាក់ប៉ុណ្ណោះដែលតម្រូវឲ្យចូលរួមក្នុងការវាយតម្លៃមែនទេ?

**ចម្លើយ ៖** ឪពុក ឬម្ដាយនីមួយៗដែលទទួលជំនួយសាច់ប្រាក់ TANF ត្រូវតែចូលរួមក្នុងការវាយតម្លៃដើម្បីស្គាល់តម្រូវការគ្រួសារ ។ តម្រូវការការចូលរួម WorkFirst នឹងត្រូវផ្អែកលើលទ្ធផលនៃការវាយតម្លៃនេះ ។ បើឪពុកម្ដាយទាំងពីរនាក់នៅផ្ទះ ឪពុក ឬម្ដាយ (ប៉ុន្តែមិនមែនទាំងពីរនាក់) អាចយកការលើកលែងទារកនៅពេលណាមួយ ។

**សំណួរ ៖** តើខ្ញុំនឹងដឹងយ៉ាងដូចម្ដេច បើដល់ពេលវេលាធ្វើការវាយតម្លៃ?

**ចម្លើយ ៖** ក្នុងករណីជាច្រើន អ្នកឯកទេសបុគ្គលិកសង្គម ឬអ្នកគ្រប់គ្រងសំណុំរឿងរបស់អ្នកនឹងផ្ញើឲ្យអ្នកនូវលិខិតណាត់ជួប ។ បើអ្នកមិនអាចមកការិយាល័យ ពួកគេអាចជួបនៅផ្ទះរបស់អ្នក ឬបំពេញការវាយតម្លៃតាមទូរស័ព្ទ ។ ទាក់ទងអ្នកឯកទេសបុគ្គលិកសង្គមរបស់អ្នកសម្រាប់ព័ត៌មានបន្ថែមលើជម្រើសទាំងនេះ ។



អ្នកគ្រប់គ្រងសំណុំរឿង WorkFirst ____________________

ទូរស័ព្ទ ____________________

បុគ្គលិកសង្គម WorkFirst ____________________

ទូរស័ព្ទ ____________________

Washington State
Department of Social
& Health Services

*Transforming lives*

DSHS 22-1262 CA (Rev. 7/15)

# ការមានផ្ទៃពោះដល់ផ្លូវការងារ



តើខ្ញុំអាចសង្ឃឹមអ្វីខ្លះពេលដែលខ្ញុំជាផ្នែកនៃការមានផ្ទៃពោះដល់ផ្លូវការងារ?



## តើនរណាជាផ្នែកនៃការមានផ្ទៃពោះដល់ផ្លូវការងារ?

អ្នកជាផ្នែកនៃការមានផ្ទៃពោះដល់ផ្លូវការងារ បើអ្នកទទួលបានជំនួយសាច់ប្រាក់ TANF (ជំនួយបណ្ដោះអាសន្នដល់គ្រួសារក្រីក្រ) និងអ្នកមានផ្ទៃពោះ ឬថែទាំកូនដែលមានអាយុក្រោម 12 ខែ ។

## តើអ្វីជាគោលដៅនៃការមានផ្ទៃពោះដល់ផ្លូវការងារ?

### *កសាងគ្រួសារដែលមានសុខភាពល្អ*

ជួយគ្រួសារចូលរួមក្នុងសកម្មភាព WorkFirst ដោយជួយពួកគេបំពេញតម្រូវការវេជ្ជសាស្ត្រ និងតម្រូវការផ្សេងទៀតរបស់គ្រួសារ។

### *ជួយគ្រួសារដើម្បីក្លាយជាម្ចាស់ការលើខ្លួនឯង*

មានជំហានជាច្រើនក្នុងការមានផ្ទៃពោះដល់ផ្លូវការងារ ។ អ្នកអាចឆ្លងកាត់ពួកវាទាំងអស់ ឬតែជំហានខ្លះប៉ុណ្ណោះ ។ វានឹងផ្អែកលើដំណាក់កាលណានៃការមានផ្ទៃពោះដែលអ្នកស្ថិតនៅ ។

បើអ្នកទើបតែទទួលបានកម្មវិធី TANF ជំហានដំបូងរបស់អ្នកនឹងជា ***ដំណើរការវាយតម្លៃគ្រប់ជ្រុងជ្រោយ*** ។

### *ការវាយតម្លៃការមានផ្ទៃពោះដល់ការងារ*

ជំហានបន្ទាប់របស់អ្នកគឺ ចូលរួមក្នុង និងបំពេញការវាយតម្លៃការមានផ្ទៃពោះដល់ការងារជាមួយអ្នកឯកទេសបុគ្គលិកសង្គម WorkFirst ។

ការវាយតម្លៃនឹង ៖

- ស្គាល់តម្រូវការ ភាពខ្លាំង និងរបាំងដែលអាចមានរបស់គ្រួសារអ្នក
- ស្គាល់សេវាកម្មដែលអ្នកអាចមានសិទ្ធិទទួលបាន ខណៈដែរអ្នកស្ថិតក្នុងការមានផ្ទៃពោះដល់ផ្លូវការងារ
- កំណត់ការចូលរួមដែលតម្រូវឲ្យមានរបស់អ្នក និងស្គាល់សកម្មភាព WorkFirst សមរម្យ



## ការចូលរួម WorkFirst ក្នុងត្រីមាសទីមួយ និងទីពីរ

បើអ្នកស្ថិតក្នុងត្រីមាសទីមួយ ឬទីពីរ (បីទៅប្រាំមួយខែ) នៃការមានផ្ទៃពោះអ្នកនឹងត្រូវបានតម្រូវឲ្យចូលរួមពេញម៉ោង ឬស្ទើរតែពេញម៉ោងតាមតែអាចធ្វើបានក្នុងសកម្មភាព WorkFirst ។ ការចូលរួមពេញម៉ោងគឺពី 32-40 ម៉ោងក្នុងមួយសប្ដាហ៍ ។

លទ្ធផលនៃការវាយតម្លៃគ្រប់ជ្រុងជ្រោយ និងការវាយតម្លៃការមានផ្ទៃពោះដល់ការងារនឹងកំណត់រយៈពេលប៉ុន្មានដែលអ្នកត្រូវចូលរួម ។

## ការចូលរួម WorkFirst ក្នុងត្រីមាសទីបី

ផ្អែកលើលទ្ធផលនៃការវាយតម្លៃរបស់អ្នក ពួកយើងនឹងកំណត់ថាតើអ្នកជា ៖



- អ្នកចូលរួម WorkFirst ដោយស្ម័គ្រចិត្ត ឬ
- អ្នកចូលរួម WorkFirst ដែលតម្រូវដោយច្បាប់ ឬ
- មានសិទ្ធិជ្រើសរើសមិនចូលរួមក្នុងសកម្មភាព WorkFirst ។

## ការចូលរួម WorkFirst សម្រាប់ឪពុកម្ដាយមានកូនទើបនឹងកើតដល់អាយុ 12 ខែ

ក្រោយពីអ្នកសម្រាល អ្នកត្រូវតែបំពេញការវាយតម្លៃការមានផ្ទៃពោះដល់ការងារ ។

ការវាយតម្លៃនេះនឹងកំណត់កម្រិតចូលរួម WorkFirst របស់អ្នក ។ អ្នកអាចត្រូវបាន ៖

- ចាត់ទុកជាអ្នកចូលរួម WorkFirst ដោយស្ម័គ្រចិត្ត
- ចាត់ទុកជាអ្នកចូលរួម WorkFirst ដែលតម្រូវដោយច្បាប់
- អាចជ្រើសរើសការលើកលែងទារក (អ្នកអាចប្រើការលើកលែងនេះដល់ 365 ថ្ងៃ ឬ 12 ខែក្នុងមួយជីវិតរបស់អ្នក មុនថ្ងៃកំណើតមួយឆ្នាំរបស់កូនអ្នក ។)

បើអ្នកមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ការលើកលែងទារក អ្នកអាចជ្រើសរើសមិនចូលរួមក្នុងសកម្មភាព WorkFirst ។ ដើម្បីមានគុណសម្បត្តិគ្រប់គ្រាន់ អ្នកត្រូវតែចូលរួមក្នុងការវាយតម្លៃដែលតម្រូវឲ្យមាន ។

## WAC 388-310-1450

បើអ្នកមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ការលើកលែងទារក អ្នកអាចជ្រើសរើសមិនចូលរួមក្នុងសកម្មភាព WorkFirst ។ ដើម្បីមានគុណសម្បត្តិគ្រប់គ្រាន់ អ្នកត្រូវតែចូលរួមក្នុងការវាយតម្លៃដែលតម្រូវឲ្យមាន ។

គោលដៅរបស់យើងគឺដើម្បីកសាងគ្រួសារដែលមានសុខភាពល្អ មិនមែនដាក់ពិន័យពួកគេទេ ប៉ុន្តែអ្នកត្រូវតែធ្វើផ្នែករបស់អ្នក និងចូលរួមក្នុងការមានផ្ទៃពោះដល់ផ្លូវការងារដូចបានតម្រូវឲ្យធ្វើ ។